


## ទីក្រុងអាសូ

# សៀវភៅជំនួយដល់ការរស់នៅរបស់ជនបរទេស




## 日本人の方へ

普段の生活、避難所、医療機関、学校、職場などで、困っている外国人の方がいらっしゃったら是非サポートをよろしくお願いいたします。外国人の方とコミュニケーションの助けとなるツールもぜひ役立ててください。

### 多言語医療問診票

日本で暮らす外国人の方が病院へ行くとき、病気やケガの症状を医師に説明する手助けをするためのカードです。

### 多言語避難者登録カード

災害が起きたときに、避難所にきた外国人の方が住所・状況・健康状態などの情報を書き込めるカードです。




យើងសង្ឃឹមថាអ្នកទាំងអស់គ្នាដែលបានមកពីបរទេស មករស់នៅអាសូនិងអាចធ្វើអោយជីវិតរបស់អ្នកទំាងគ្នាកាន់តែសំបូរសប្បាយ អាសូជាទីក្រុងដែលមានភាពងាយស្រួលក្នុងការរស់នៅ សូមរីករាយក្នុងរស់នៅក្រុងអាសូជាមួយនិងភាពទាក់ទាញរបស់ក្រុងអាសូ

## ស្វែងរកផ្លូវធ្វើដំណើរ

### តាមឡាន

គីម៉ាម៉ូតូIC — ផ្លូវរដ្ឋលេខ57 — ប្រហែល60នាទី — ក្រុងអាសូ

ហ៊ីតាIC — ផ្លូវរដ្ឋលេខ212 — ប្រហែល1ម៉ោង40នាទី — ក្រុងអាសូ

### តាមរថភ្លើងJR

ស្ថានីយ៍រថភ្លើងគីម៉ាម៉ូតូ — ខ្សែរថភ្លើងJRហូហ៊ី [TRANS-KYUSHU LIMITED EXPRESS] ប្រហែល60នាទី — ស្ថានីយ៍រថភ្លើងអាកាមីស៊ុ

ប្រហែល10នាទី

ស្ថានីយ៍រថភ្លើងអាសូ — ប្រហែល5នាទី — ស្ថានីយ៍រថភ្លើងមីយ៉ាឌី

### ករណីរើសផ្ទះដោយជិះយន្តហោះ

#### ពីអាសូទៅនិងមកព្រលានយន្តហោះគីម៉ាម៉ូតូដោយជិះឡាន

អាសូគីម៉ាម៉ូតូព្រលានយន្តហោះ — តាមផ្លូវខេត្តលេខ36 ផ្លូវរដ្ឋលេខ443និងផ្លូវរដ្ឋលេខ57 ប្រហែល45នាទី — ក្រុងអាសូ

#### ពីអាសូទៅនិងមកព្រលានយន្តហោះគីម៉ាម៉ូតូដោយជិះឡានក្រុង

អាសូគីម៉ាម៉ូតូព្រលានយន្តហោះ — ក្រុមហ៊ុនឡានក្រុងkyusyusanko [ឡានក្រុងល្បឿនលឿនyamabiko (ទៅខេត្តអូអ៊ីតា)] ប្រហែល60នាទី — ស្ថានីយ៍រថភ្លើងអាសូ

ការពិគ្រោះ និងសាកសួរអំពីការរស់នៅទីក្រុងអាសូ


នាយកដ្ឋានសេដ្ឋកិច្ចទីក្រុងអាសូ ផ្នែកផែនការកសាងទីក្រុង
〒869-2695 ខេត្តគីម៉ាម៉ូតូ ក្រុងអាសូសង្កាត់អីឌីណូមីយ៉ាឌីតំបន់មីយ៉ាឌី504-1
TEL. 0967-22-3318 / FAX. 0967-22-4566
[ម៉ែល] machizukuri@city.aso.lg.jp



គម្រោងនេះត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីក្រុមប្រឹក្សាអាជ្ញាធរមូលដ្ឋានសម្រាប់ទំនាក់ទំនងអន្តរជាតិ


គេហទំព័រផ្លូវការរបស់ក្រុងអាសូ

អាសូពិតជាល្អមែន! [គេហទំព័រសមាគមន៍ទេសចរណ៍ទីក្រុងអាសូ]

គណនេយ្យផ្លូវការ Instagramរបស់ក្រុងអាសូ @asostagram



# ក្រុងអាសូសូមស្វាគមន៍

ទីក្រុងអាសូ គឺជាទីក្រុងដ៏មានមន្តស្នេហ៍ដែលមានទីតាំងនៅជើងភ្នំអាសូ ដែលអ្នកអាចរីករាយនឹងធម្មជាតិ ទឹកក្តៅ និងអាហារឆ្ងាញ់ៗ យើងនឹងគាំទ្រអ្នកដើម្បីឱ្យអ្នកមានភាពរីករាយរាល់ថ្ងៃ

### ទេសចរណ៍



មានភ្ញៀវទេសចរណ៍ជាង 16 លាននាក់ក្នុងមួយឆ្នាំ បានមកទស្សនាសម្រស់ធម្មជាតិរបស់វា រួមទាំងភ្នំភ្លើងដ៏ធំបំផុតមួយលំដាប់ពិភពលោក រួមទាំងភាពទាក់ទាញនៃប្រវត្តិសាស្ត្រ និងវប្បធម៌របស់វា

ពត៌មានទេសចរណ៍មាននៅទីនេះ →

### មធ្យោបាយធ្វើដំណើរក្នុងក្រុង



ឡាន កង ឡានក្រុង រថភ្លើងជាមធ្យោបាលធ្វើដំណើរចំបង តំបន់ដែលគ្មានឡានក្រុងនិងរថភ្លើង ប្រជាជនអាចប្រើប្រាស់តាក់ស៊ីជិះរួមគ្នា

ពត៌មានឡានក្រុង រថភ្លើង →

ពត៌មានតាក់ស៊ីជិះរួមគ្នា →

### អាកាសធាតុ



សីតុណ្ហភាពជាមធ្យមគឺប្រហែល 13°C គឺអាកាសធាតុត្រជាក់ស្រួលពេញមួយឆ្នាំ រដូវរងាត្រជាក់ខ្លាំង និងអាចមានព្រិលធ្លាក់

## របៀបប្រើប្រាស់សៀវភៅនោះ

សៀវភៅនេះអាចអោយយើងទទួលបានពត៌មានដែលមានប្រយោជន៍សម្រាប់ការរស់នៅក្រុងអាសូ

### ដើម្បីពត៌មានជាភាសាប្រទេសអ្នក

ប្រសិនបើអ្នកក្រឡេកមើលសៀវភៅនេះដោយប្រើកាមេរ៉ារបស់ Google Translate អ្នកអាចបកប្រែវាទៅជាភាសារបស់ប្រទេសរបស់អ្នក។

ទាញយកកម្មវិធី

ទាញយកកម្មវិធីរបស់ទូរសព្ទAndroid | ទាញយកកម្មវិធីរបស់ទូរសព្ទIPHONE

ស្វែងរក

លិខិតប័ណ្ណមានជាភាសាអង់គ្លេស ខ្មែរ និងវៀតណាម យើងអាចទាញយកតាមគេហទំព័រសាលាក្រុងអាសូក៏បាន យកនៅសាលាក្រុងក៏បាន

### សូមប្រើប្រាស់អ៊ីនធឺណិត

នៅពេលឆែកអ៊ីនធឺណិតដោយប្រើGoogleChromeអ្នកអាចឃើញពត៌មានផ្សេងៗជាភាសារបស់អ្នក

ទាញយកកម្មវិធី

ទាញយកកម្មវិធីរបស់ទូរសព្ទAndroid | ទាញយកកម្មវិធីរបស់ទូរសព្ទIPHONE



គោលបំណង


P.1 នៅពេលមានបញ្ហា កាណែនំារបស់សាលាក្រុងអាសូ

P.2 សូមស្វាគមន៍មកកាន់ទីក្រុងអាសូ របៀបប្រើប្រាស់កូនសៀវភៅ

P.3 ការចោលសំរាម

P.4 អគ្គិសនី ហ្គាស ប្រព័ន្ធទឹកស្អាត ប្រៃសណីយ៍

P.5 ទាក់ទងនឹងគ្រោះមហន្តរាយ (ដូចជាការរញ្ជួយដី និងព្យុះទីហ្វុង)។

P.6 ជំងឺ មានរបួស គ្រោះថ្នាក់ បទល្មើស




# នៅពេលមានបញ្ហា


ចង់ចោលសំរាម — ទៅទំព័រទី3

ភ្លើង ហ្គាស ប្រពន្ធ័ទឹក — ទៅទំព័រទី4

ទាក់ទងនឹងគ្រោះមហន្តរាយ (ដូចជាការរញ្ជួយដី និងព្យុះទីហ្វុង)។ — ទៅទំព័រទី5

ស្តីអំពីជំងឺ របួស គ្រោះថ្នាក់ បទល្មើស — ទៅទំព័រទី6


ប្រសិនបើអ្នកមានបញ្ហាអ្វីផ្សេងទៀត សូមមកកាន់សាលាក្រុងអាសូ។

## កន្លែងផ្តល់ពត៌មាននៅសាលាក្រុងអាសូ

សាលាក្រុងអាសូមានផ្តល់ការប្រឹក្សាលើបញ្ហាជាច្រើនរួមទាំងនីតិវិធីរដ្ឋបាល និងជីវភាពរស់នៅប្រចាំថ្ងៃ

ការស្រាវជ្រាវផែនទី

កម្មវិធីបកប្រែជាសំលេង

នៅកន្លែងផ្តល់ពត៌មានសូមប្រើកម្មវិធីបកប្រែជាសំលេង ដើម្បីអោយមានភាពងាយស្រួល

ទាញយកកម្មវិធីរបស់ទូរសព្ទAndroid | ទាញយកកម្មវិធីរបស់ទូរសព្ទIPHONE

### ការធានារ៉ាប់រងសុខភាពជាតិ ប្រាក់សោធននិវត្តន៍

ផ្នែកធានារ៉ាប់រង
(ទីស្នាក់ការកណ្តាលជាន់ទី1)
TEL：0967-22-3145

### បញ្ហាពន្ធដារ

នាយកដ្ឋានពន្ធដារ
(ទីស្នាក់ការកណ្តាលជាន់ទី1)
TEL：0967-22-3148

### ប្រសិនបើអ្នកមានផ្ទៃពោះ

ផ្នែកលើកកម្ពស់សុខភាព
(មជ្ឈមណ្ឌលសុខភាពទីស្នាក់ការកណ្តាល)
TEL：0967-22-5088

### ការផ្លាស់ប្តូរកន្លែងរស់នៅ

ផ្នែកប្រជាជន
(ទីស្នាក់ការកណ្តាលជាន់ទី1)
TEL：0967-22-3135

### ករណីមានបញ្ហាហិរញ្ញវត្ថុ ឬការងារ

មជ្ឈមណ្ឌលពិគ្រោះការរស់នៅ
(អគារឧបសម្ព័ន្ធខាងកើតនៃការិយាល័យធំ)
TEL：0967-22-3364

### ការរៀបការ

ផ្នែកប្រជាជន
(ទីស្នាក់ការកណ្តាលជាន់ទី1)
TEL：0967-22-3135

## ការណែនាំអំពីសាខា សាលាក្រុងអាសូ

សាលាក្រុងក្រៅអំពីទីស្នាក់កាលកណ្តាល មានសាខាគ្រប់តំបន់ វាមានភាពងាយស្រួលក្នុងការប្រើប្រាស់សូមប្រើប្រាស់សាខាដែលនៅជិតអ្នក

ពត៌មានស្តីអំពីទីស្នាក់ការកណ្តាល សាខាមាននៅទីនេះ →

### សាលាក្រុងអ៊្វជីណូម៉ាគី

〒869-2301
ក្រុងអាសូស្រុកអ៊្វជីណូម៉ាគី1111-3
TEL：0967-32-1111

ការស្រាវជ្រាវផែនទី

### សាលាក្រុងណាមីណូ

〒869-2806
ក្រុងអាសូស្រុកណាមីណូអូស្យាណាមីណូ2703
TEL：0967-24-2001

ការស្រាវជ្រាវផែនទី

## ជូនចំពោះជនបរទេសទាំងអស់ដែលមានកាតលេខសំគាល់ខ្លួន

**សូមប្រុងប្រយ័ត្ន** នៅពេលពន្យាររយៈពេលប័ណ្ណស្នាក់នៅ ពត៌មាននៅកាតលេខសំគាល់ខ្លួនក៏ត្រូវផ្លាស់ប្តូរដែរ

កាលណាសុពលភាពនៃកាតលេខសំគាល់ខ្លួនផុតកំណត់ហើយយើងមិនបានទៅសាលាក្រុងបន្តសុពលភាពនោះកាតរបស់យើងនិងប្រើប្រាស់លែងបាន (វាជាកាត IC ធ្វើអំពីប្លាស្ទិកដែលមានបិទរូបថត)



※បន្ទាប់ពីបានបន្តសុពលភាពនៃប័ណ្ណស្នាក់នៅរួចហើយ ថ្ងៃផុតសុពលភាពនៃប័ណ្ណថ្មី មិនត្រូវបានចម្លងទៅកាតលេខសំគាល់ខ្លួនដោយស្វ័យប្រវត្តិនោះទេ អ្នកដែលមានកាតលេខសំគាល់ខ្លួន ត្រូវទៅសាលាក្រុងរៀបចំនិតិវិធី

※ប្រសិនបើអ្នកផ្លាស់ប្តូរអាស័យដ្ឋានឬឈ្មោះនៅលើប័ណ្ណស្នាក់នៅ អ្នកត្រូវទៅរាយការណ៍មិនអោយលើស14ថ្ងៃបន្ទាប់ពីផ្លាស់ប្តូររួច

កន្លែងសាកសួរពត៌មាន នៅផ្នែកប្រជាជន

# 1 ការចោលសំរាម



ថ្ងៃចោលសំរាមអាចខុសគ្នាតាមតំបន់យើងរស់នៅ នៅថ្ងៃចោលសំរាមត្រូវយកសំរាមទៅដាក់នៅកន្លែងចោលអោយបានត្រឹមត្រូវឬមុនម៉ោង8កន្លះព្រឹក នៅពេលមិនស្គាល់កន្លែងចោលសំរាមត្រូវសួរមេភូមិម្ចាស់ផ្ទះឬក្រុមហ៊ុនមើលការខុសត្រូវផ្ទះ

## របៀបចោលសំរាម

តារាងថ្ងៃប្រមូលសំរាមតាមភូមិស្រុកនីមួយៗ →

**STEP 1**



កំប៉ុងនិងដបប្លាស្ទិកជាដើមត្រូវលាងសំអាតខាងក្នុង

**STEP 2**



សំរាមត្រូវបែងចែកតាមប្រភេទ សូមមើលតារាងបែងចែក និងបែងចែកតាមតារាង

**STEP 3**



ត្រូវដាក់ចូលថង់ដែលបានកំណត់

ថង់សំរាមអាចទិញបាននៅផ្សារ ម៉ាត់ ជាដើម

**STEP 4**



សំរាមត្រូវចោលនៅថ្ងៃនិងទីកន្លែងដែលបានកំណត់

ត្រូវយកដាក់អោយមុនឬត្រឹមម៉ោង8កន្លះព្រឹក

## ក្បួនបែងចែក

របៀបបែងចែកសំរាមផ្ទះបាយនិងបោះចោលសំរាមរបស់ក្រុងអាសូ →

### សំរាមសំណល់ឥន្ធនៈរឹង



ក្រដាសសំណល់ កាកសំណល់អាហារ ផ្លាស្ទិច ស្បែក ក្រណាត់ កៅស៊ូ វីនីល ជាដើម។

ត្រូវដាក់ក្នុងថង់ដែលបានកំណត់(ថងពណ៌លឿង)

### សំរាមកែច្នៃបានកំប៉ុង កែវ



ប្រភេទកំប៉ុងនិងកែវសម្រាប់ដាក់ទឹកបរិភោគ

ត្រូវដាក់ក្នុងថង់ដែលបានកំណត់(ថង់ថ្លា)

### សំរាមកែច្នៃបានដបប្លាស្ទិក



ដបប្លាស្ទិកប្រើសម្រាប់ដាក់ទឹកបរិភោគ

※ ដោះម្ដូក។

ត្រូវដាក់ក្នុងថង់ដែលបានកំណត់(ថង់ថ្លា)

### ទស្សនាវដ្ដី ប្រភេទក្រដាសផ្សេងទៀត



ទស្សនាវដ្ដីត្រូវចងនិងបែងចែកតាមប្រភេទ

### សំរាមកែច្នៃបាន(សំលៀកបំពាក់ ប្រភេទក្រណាត់)



អាវ ខោ អាវយឺត អាវក្រណាត់ជាដើម

ខោអាវក្នុងជាសំរាមសំណល់ឥន្ធនៈរឹង

ត្រូវដាក់ក្នុងថង់ដែលបានកំណត់(ថង់ថ្លា)

### កេស



យកខ្សែរចង

### ក្រដាសកាសែត ក្រដាសផ្សព្វផ្សាយ



យកខ្សែរចង

### ប្រអប់ទឹកដោះគោ



យកខ្សែរចង

### សំរាមដុតមិនឆេះ



ប្រភេទលោហៈ កញ្ចក់ សេរ៉ាមិច កំប៉ុងបាញ់ជាដើម

កំប៉ុងហ្គាសត្រូវយកហ្គាសចេញអោយអស់

ត្រូវដាក់ក្នុងថង់ដែលបានកំណត់(ថង់ពណ៌ខៀវ)



# 2 អគ្គិសនី ហ្គាស ប្រព័ន្ធទឹកស្អាត



## អគ្គិសនី ហ្គាស ប្រព័ន្ធទឹកស្អាត

ប្រសិនបើយើងកំណត់ថ្ងៃរស់នៅក្រុងអាសូហើយ យើងអាចស្នើរសុំថ្ងៃចាប់ផ្ដើមប្រើប្រាស់បាន ប្រសិនបើអ្នកមានបញ្ហាណាមួយ សូមទាក់ទងមកលេខខាងក្រោមនេះ

| ប្រភេទ | កន្លែងសាកសួរពត៌មាន | ដោយវិធីណា | ការបង់ប្រាក់ | លេខទំនាក់ទំនង |
| --- | --- | --- | --- | --- |
| អគ្គីសនី | ក្រុមហ៊ុនអគ្គិសនី។ | ទូរស័ព្ទ គេហទំព័រ | ម្ដងក្នុងមួយខែ | សូមទាក់ទងទៅគ្រប់ក្រុមហ៊ុនថាមពលអគ្គិសនីក្នុងតំបន់របស់អ្នក |
| ហ្គាស | ក្រុមហ៊ុនឧស្ម័ន។ | ទូរស័ព្ទ គេហទំព័រ<br>នៅពេលចាប់ផ្ដើមប្រើ និងពេលឈប់ប្រើបុគ្គលិកក្រុមហ៊ុនហ្គាសនិងមក | ម្ដងក្នុងមួយខែ | អាចខុសគ្នាតាមកន្លែងរស់នៅ<br>សូមសាកសួរម្ចាស់ផ្ទះឬក្រុមហ៊ុនមើលការខុសត្រូវផ្ទះ |
| ប្រព័ន្ធទឹកស្អាត | ផ្នែកគ្រប់គ្រងប្រព័ន្ធទឹកស្អាត<br>មីយ៉ាឆី អ៊ូជីណូម៉ាគី កុចូ(សង្កាត់លេខ1～3 និងសង្កាត់លេខ2) គូរ៉ូការ៉ា ណាហ្គាមីស្សិ យ៉ាម៉ាដា អូហ្គាអ៊ីស៊ី ណាមីណូ តំបន់ក្រៅពីតំបន់ខាងក្រោម | បញ្ជូរទូរស័ព្ទ /សាលាក្រុង។ | ម្ដងក្នុងមួយខែ | TEL：0967-22-3196<br>(ការិយាល័យកណ្ដាលផ្នែកគ្រប់គ្រងប្រព័ន្ធទឹកស្អាត)<br>TEL：0967-32-2731<br>(សាខាស្រុកអ៊ូជីណូម៉ាគី)<br>TEL：0967-24-2001<br>(សាខាស្រុកណាមីណូ)<br>សូមខលទៅទីតាំងដែលនៅជិតអ្នករស់នៅ<br>(បើកដំណើរការពីម៉ោង8កន្លះព្រឹកដល់ម៉ោង5ល្ងាច)<br>សម្រាកថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃបុណ្យជាតិ |
| | ទ្រព្យសម្បត្តិតំបន់ សមាជិកគណៈកម្មាធិការសង្កាត់ ឬក៏ផ្នែកផែនការ និងហិរញ្ញវត្ថុ<br>សាកាណាស៊ី ណាកាដូរី កុចូ(សង្កាត់លេខ4～7) | បញ្ជូរទូរស័ព្ទ /សាលាក្រុង។ | សាកាណាស៊ី ម្ដងក្នុងមួយឆ្នាំ<br>ណាកាដូរី ម្ដងក្នុងមួយខែ<br>កុចូ(សង្កាត់លេខ4～7) ម្ដងរៀងរាល់ 3 ខែ | TEL：0967-22-3204<br>(ផ្នែកផែនការ និងហិរញ្ញវត្ថុ)<br>(បើកដំណើរការពីម៉ោង8កន្លះព្រឹកដល់ម៉ោង5ល្ងាច)<br>សម្រាកថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃបុណ្យជាតិ |

ប្រព័ន្ធទឹកស្អាតនៅក្រុងអាសូ「ជាទឹកធម្មជាតិនៅក្រោមដី」វាមានរស់ជាតិឆ្ងាញ់ហើយយើងអាចបរិភោគ



## ប្រៃសណីយ៍

នៅការិយាល័យប្រៃសណីយ៍ អ្នកអាចផ្ញើប្រាក់ និងទំនិញ បើកគណនីធនាគារប្រៃសណីយ៍ជប៉ុនបាន ការិយាល័យប្រៃសណីយ៍ និងប្រអប់សំបុត្រត្រូវបានតំណាងដោយនិមិត្តសញ្ញា "〒"




ការិយាល័យប្រៃសណីយ៍នៅក្នុងក្រុងអាសូ →

របៀបប្រើការិយាល័យប្រៃសណីយ៍ →

### ការផ្ញើរឥវ៉ាន់ទៅក្រៅប្រទេសតាមប្រៃសណីយ៍អន្តរជាតិ

ណែនាំអំពីវិធីផ្ញើរឥវ៉ាន់ទៅក្រៅប្រទេស

របៀបផ្ញើឥវ៉ាន់ទៅក្រៅប្រទេស៖ ការណែនាំសម្រាប់អ្នកចាប់ផ្ដើមដំបូង →

យើងអាចផ្ញើរឯកសារជាដើមទៅក្រៅប្រទេសបាន

ត្រូវបង្កើតគេហទំព័រប្រៃសណីយ៍អន្តរជាតិផ្ទាល់ខ្លួន →

# 3 ទាក់ទងនឹងគ្រោះមហន្តរាយ (ដូចជាការរញ្ជួយដី និងព្យុះទីហ្វុង)។

ការប្រមូលពត៌មានដែលមានប្រយោជន៍សម្រាប់ការ ការពារគ្រោះមហន្តរាយណ៍ដែលមានច្រើនភាសា

ស្វែងរក

ចុចទីនេះសម្រាប់ព័ត៌មានបន្ថែមអំពីគ្រោះមហន្តរាយ

## គ្រោះមហន្តរាយណ៍ដែលអាចកើតមាននៅក្រុងអាសូ

### ការរញ្ជួយដី

ផ្ទៃដីមានរំញ័រ នៅពេលមានរញ្ជួយដីខ្លាំងសំណង់អគារអាចដួលរលំ និងអាចមានអគ្គីភ័យកើតឡើង

### ភ្លៀងធ្លាក់ខ្លាំង

ភ្លៀងធ្លាក់ខ្លាំងក្នុងរយៈពេលខ្លីត្រូវបានគេហៅថាភ្លៀងធ្លាក់ខ្លាំងដែលអាចបង្កើនហានិភ័យនៃការបាក់ដីខ្លាំង

### ខ្យល់ព្យុះ

ភ្លៀងធ្លាក់ខ្លាំងនិងខ្យល់បក់ខ្លាំងពីរដូវក្តៅដល់រដូវស្លឹកឈើជ្រុះមកជិតប្រទេសជប៉ុនច្រើន

### ការផ្ទុះភ្នំភ្លើង

ការកើតបាតុភូតម៉ាកម៉ានិងផេះភ្នំភ្លើងផ្ទុះអាចមានថ្មភ្នំភ្លើងនិងផេះភ្នំភ្លើងផ្ទុះធ្លាក់មក

## ការត្រៀមពេលមានគ្រោះមហន្តរាយណ៍

ជប៉ុនជាប្រទេសមានគ្រោះមហន្តរាយណ៍ច្រើន ដើម្បីសុវត្ថិភាពសូមគិតអំពីការការពារគ្រោះមហន្តរាយណ៍ជាប្រចាំ

### កម្មវិធីការពារគ្រោះមហន្តរាយណ៍

**កម្មវិធីការពារគ្រោះមហន្តរាយណ៍របស់ទីក្រុងអាសូ**

សេចក្តីជូនដំណឹងស្តីពីការការពារគ្រោះមហន្តរាយណ៍និងពត៌មានអាកាសធាតុសម្រាប់ទីក្រុងអាសូ

ទាញយកកម្មវិធីរបស់ទូរសព្ទAndroid / ទាញយកកម្មវិធីរបស់ទូរសព្ទIPHONE

**ផែនទីជម្លៀសខ្លួនពេលមានអាសន្នរបស់ទីក្រុងអាសូ (ផែនទីសង្គ្រោះពេលគ្រោះមហន្តរាយណ៍)**

អាចឆែកមើលទីតាំងជម្លៀសខ្លួននៅពេលមានអាសន្នរបស់ក្រុងអាសូបាន

គេហទំព័រ

**គន្លឹះសុវត្ថិភាព**

សេចក្តីជូនដំណឹងអំពីពត៌មានគ្រោះមហន្តរាយណ៍នៅក្នុងប្រទេសជប៉ុន

ទាញយកកម្មវិធីរបស់ទូរសព្ទAndroid / ទាញយកកម្មវិធីរបស់ទូរសព្ទIPHONE

**ពត៌មានពិភពលោករបស់NHKជប៉ុន**

ការផ្សព្វផ្សាយពត៌មានតាមNHK

ទាញយកកម្មវិធីរបស់ទូរសព្ទAndroid / ទាញយកកម្មវិធីរបស់ទូរសព្ទIPHONE

## ពត៌មានក៏ត្រូវបានផ្សព្វផ្សាយតាមរយៈស្ថានីយជូនដំណឹងផងដែរ

ស្ថានីយពត៌មានដែលចែកចាយពត៌មានបង្ការគ្រោះមហន្តរាយណ៍យ៉ាងឆាប់រហ័សការផ្សាយជូនភ្លាមៗក្នុងករណីមានអគ្គីភ័យឬគ្រោះមហន្តរាយណ៍ ប្រសិនបើមានបណ្ណ័ប្រជាជនយើងអាចតំឡើងដោយមិនអស់ប្រាក់សូមតំឡើង



### ទីកន្លែងស្នើរសុំតំឡើង

ការិយាល័យគ្រប់គ្រងពត៌មាន ផ្នែកពត៌មានគ្រោះមហន្តរាយណ៍របស់សាលាក្រុងអាសូ

〒869-2695 ក្រុងអាសូ សង្កាត់អីឆីណូមីយ៉ាតំបន់មីយ៉ាឆី504-1

TEL：0967-22-3253

## ត្រូវត្រៀមជានិច្ចសម្រាប់គ្រោះមហន្តរាយណ៍ដែលអាចកើតមាន

នៅពេលមានគ្រោះមហន្តរាយណ៍កើតឡើងភ្លើងហ្គាសនិងទឹកជាដើមអាចនិងដាច់ប្រើមិនបានរបស់ញ៉ាំនិងទឹកជាដើមអាចនិងទិញមិនបាន ត្រូវទិញនិងរៀបចំរបស់ប្រើប្រាស់ដែលចំបាច់ដើម្បីត្រៀមពេលមានអាសន្ន

### នៅពេលរៀបចំទុកដាក់ ធ្វើអោយយើងស្ងប់ចិត្ត

ត្រូវរៀបចំទុកដាក់ក្នុងកាតាបស្ពាយអោយហើយ ពេលមានអាសន្នអាចយកទៅបានភ្លាមៗ ទឹកនិងរបស់ញ៉ាំត្រូវទិញទុកជានិច្ចដើម្បីត្រៀមទុក

| | | | |
|---|---|---|---|
| ☑ របស់ញ៉ាំ | ☑ ប័ណ្ណស្នាក់នៅ | ☑ បង្គន់ចល័ត | ☑ ម៉ាស់ |
| ☑ ទឹកបរិភោគ | ☑ ឧបករណ៍សាកថ្មទូរស័ព្ទ | ☑ អាស័យដ្ឋានទំនាក់ទំនងរបស់ស្ថានទូត | ☑ កន្សែង |
| ☑ ឧបករណ៍សង្គ្រោះបន្ទាន់ | ☑ លិខិតឆ្លងដែន | ☑ ឧបករណ៍ការពារអាកាសធាតុត្រជាក់ ភួយអាលុយមីញ៉ូម | ☑ សំភារៈអនាម័យសំរាប់ស្ត្រី |
| ☑ ពិលLED | ☑ សាច់ប្រាក់(កាក់) | ☑ ផ្លាកស្និចរុំ ចង្កឹះប្រើហើយចោលបាន ចានក្រដាស | ☑ សំភារៈសំរាប់ទារក |
| ☑ វិទ្យុ | ☑ ផែនទី | ☑ ស្កុតក្រណាត់ | ☑ ស្បែកជើង |
| ☑ ថ្មពិល | ☑ អាវភ្លៀង | ☑ ច្រាសដុសធ្មេញ ទឹកខ្ពុរមាត់ | ☑ ស្រោមដៃ |



# 4 ជំងឺ មានរបួស គ្រោះថ្នាក់ បទល្មើស

## លេខទំនាក់ទំនងពេលបន្ទាន់

សេវាសង្គ្រោះបន្ទាន់អត់អស់ប្រាក់មាន24ម៉ោង សូមប្រើប្រាស់តែពេលបន្ទាន់

សូមទូរស័ព្ទមកខ្ញុំហើយប្រាប់ខ្ញុំ (1) មានអ្វីកើតឡើង (2) ទីតាំង (3) ឈ្មោះរបស់អ្នក (4) លេខទូរស័ព្ទរបស់អ្នក។

| ជំងឺបន្ទាន់ របួស | អគ្គីភ័យ ការពន្លត់អគ្គីភ័យ | បទល្មើស គ្រោះថ្នាក់ |
|---|---|---|
| 119 | 119 | 110 |
| សង្គ្រោះបន្ទាន់ ជំងឺបន្ទាន់ ពេលមានរបួសធ្ងន់ | ពេលមានអគ្គីភ័យនិងពេលត្រូវការជំនួយ | នៅពេលជួបគ្រោះថ្នាក់ចរាចរណ៍ឬជួបបទល្មើស |

## មន្ទីរពេទ្យ

ចុចទីនេះសម្រាប់ព័ត៌មានមន្ទីរពេទ្យ។

មានព័ត៌មានអំពីមន្ទីរពេទ្យ។

- ប្រភេទមន្ទីរពេទ្យ (តើខ្ញុំគួរទៅមន្ទីរពេទ្យមួយណា)។
- វេជ្ជបណ្ឌិតដែលបំពេញកាតព្វកិច្ចនៅផ្ទះ

មជ្ឈមណ្ឌលសង្គ្រោះបន្ទាន់នៅយប់វិស្សមកាល

(មន្ទីរពេទ្យដែលអ្នកអាចទៅវិស្សមកាល ឬពេលយប់)។

ការប្រើកម្មវិធីបកប្រែជាសំឡេងនៅពេលនិយាយវាមានភាពងាយស្រួល

កម្មវិធីបកប្រែមាននៅទីនេះ

### នៅពេលទៅមន្ទីរពេទ្យត្រូវតែយកប័ណ្ណធានារ៉ាប់រងសុខភាព(ប័ណ្ណលេខសំគាល់ខ្លួននិងប័ណ្ណស្នាក់នៅ)ទៅ

នៅពេលអ្នកទៅមន្ទីរពេទ្យនៅប្រទេសជប៉ុន អ្នកត្រូវការប័ណ្ណធានារ៉ាប់រង។ ប្រសិនបើអ្នកមិនយកប័ណ្ណធានារ៉ាប់រងរបស់អ្នកមកជាមួយអ្នកទេ ប្រាក់ដែលអ្នកបង់សម្រាប់មន្ទីរពេទ្យនឹងខ្ពស់ណាស់។

## នៅពេលអ្នកឈឺ របួស ឬអគ្គីភ័យ។

នៅពេលមានអាសន្នបន្ទាន់(ឈឺភ្លាមៗ រងរបួស)និងមានអគ្គីភ័យជាដើមត្រូវខលទៅលេខ(119)

**STEP 1**

119

ខលទៅលេខទូរស័ព្ទ(119)

**STEP 2**

នៅពេលភ្ជាប់ទូរស័ព្ទបានហើយត្រូវនិយាយ

①តើ「សង្គ្រោះបន្ទាន់」ឬក៏「អគ្គីភ័យ」

②ទីកន្លែងមានអគ្គីភ័យនិងទីកន្លែងមានអ្នករបួស

③រកមើលអគារដែលអាចធ្វើសញ្ញាសំគាល់នៅជិតនោះ

④ប្រាប់ពីស្ថានភាពនៃជំងឺ

ថ្លៃប្រើប្រាស់ឡានសង្គ្រោះបន្ទាន់មិនអស់ប្រាក់ទេ ប៉ុន្តែដោយសារឡានសង្គ្រោះបន្ទាន់ប្រើសំរាប់តែពេលមានអាសន្ន ករណីមានរបួសស្រាលជាដើមសូមកុំប្រើ

## ក្នុង ពេល មាន គ្រោះថ្នាក់ ចរាចរណ៍។

①សូមប្រាប់អំពីរឿងដែលបានកើត②ទីកន្លែង③ឈ្មោះ④លេខទូរស័ព្ទរបស់អ្នក

**STEP 1**

ត្រូវឈប់ឡានភ្លាមដើម្បីកុំអោយរំខានដល់អ្នកធ្វើដំណើរផ្សេងទៀត ត្រូវផ្លាស់ទីទៅទីតាំងដែលមានសុវត្ថិភាពដូចជាជញ្ជើមផ្លូវ និងកន្លែងដីទំនេរជាដើម

**STEP 2**

110

ខលទៅលេខប៉ូលីស(110)ហើយពេលប៉ូលីសទៅដល់ត្រូវរាយការណ៍ពីស្ថានភាពទៅកាន់ប៉ូលីស ករណីមានអ្នករងរបួសត្រូវខលទៅឡានសង្គ្រោះបន្ទាន់លេខ(119)

**STEP 3**

ទោះបីជាមិនមានរបួសឬគិតថាជារបួលស្រាលក៏ដោយ អាចពេលក្រោយទើបដឹងថាមានរបួសធ្ងន់ដូចនេះពេលមានគ្រោះថ្នាក់សូមប្រញាប់ទៅមន្ទីរពេទ្យ

**STEP 4**

ដើម្បីទទួលបានជំនួយនៅក្រោយពេលគ្រោះថ្នាក់ចរាចរណ៍ហើយ ជួលកាលអាចត្រូវការលិខិតបញ្ជាក់ថាបានជួបគ្រោះថ្នាក់ចរាចរណ៍ សូមដាក់ពាក្យស្នើរសុំនៅប៉ុស្តិ៍

### ប៉ុស្តិ៍ប៉ូលីសក្រុងអាសូ

〒869-2225 ក្រុងអាសូតំបន់គូរ៉ូកាវ៉ាលេខតំបន់1306-1

TEL：0967-35-5110

GoogleMAP

នៅក្នុងក្រុងមានប៉ុស្តិ៍ប៉ូលីសនិងចំណតរថយន្ត